

# ញត្តិជូនរដ្ឋាភិបាលកម្ពុជា

## តាមរយៈ លោក ជុំ សុន្ទរី ឯកអគ្គរាជទូតកម្ពុជាប្រចាំសហរដ្ឋអាមេរិក

យើងខ្ញុំ ជាពលរដ្ឋខ្មែរ-អាមេរិកាំង មកជួបជុំគ្នាសម្តែងមតិនៅថ្ងៃនេះ ដើម្បីផ្ញើសារសំឡេង និងការទាមទាររបស់យើងខ្ញុំ តាមរយៈលោក **ឯកអគ្គរាជទូតកម្ពុជាប្រចាំសហរដ្ឋអាមេរិក** ជូនលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** និងរដ្ឋាភិបាលរបស់លោក ។ យើងខ្ញុំ ជម្រុញលោកនាយករដ្ឋមន្ត្រីឲ្យស្តារមុខមាត់ប្រទេសកម្ពុជាឡើងវិញ ដោយដោះលែងអ្នកទោសមនសិការ និងអ្នកទោសនយោបាយទាំងអស់ ដោយគ្មានលក្ខខណ្ឌ និងជាបន្ទាន់ ។

**យើងខ្ញុំ** សូមទទូចឲ្យដោះលែងលោក **រ៉ុង ឈុន** ព្រះភិក្ខុ **កើត សារ៉ាយ** លោក **មាន ព្រហ្មមុនី** កញ្ញា **អេង ម៉ាឡៃ** (ហៅ **សូ មេត្តា**) លោក **មួង សុភក្ត្រ** លោក **ថា ឡាវី** យុវតី **ឈឿន ដារ៉ាវី** លោក **ហ៊ុន វណ្ណៈ** យុវតី **ស កន្និកា** លោក **សួង សុភ័ណ្ឌ** កញ្ញា **សាន ស្រីនិច** លោក **ថុន រដ្ឋា** កញ្ញា **តួង កែវរស្មី** កញ្ញា **ឡុង គន្ធា** លោក **គា សុគន្ធ** លោក **ឡុង ពុទ្ធារ៉ា** **និងអ្នកឯទៀត ដើម្បីពួកគាត់អាចអនុវត្តសិទ្ធិស្របតាមរដ្ឋធម្មនុញ្ញ ។ យើងខ្ញុំក៏ទទូចឲ្យទម្លាក់ចោលបទចោទនានា ប្រឆាំងនឹងអ្នកនយោបាយ និងផ្តល់សេរីភាពនយោបាយពេញលេញ ដល់ពួកគាត់ឡើងវិញ រួមមាន** លោក **គឹម សុខា** លោក **សម រង្ស៊ី** **និងសហការីទាំងអស់ នៃគណបក្សសង្គ្រោះជាតិ ។**

លោក **ឯកអគ្គរាជទូតកម្ពុជា** និងលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** *ដឹងច្បាស់ណាស់ថា* ក្រៅពីលោក **គឹម សុខា** លោក **សម រង្ស៊ី** និងសហការីជាន់ខ្ពស់ នៃគណបក្សសង្គ្រោះជាតិនោះ អ្នកទោសមនសិការគ្រប់រូប សុទ្ធតែជាសកម្មជនសង្គម និងពលរដ្ឋសាមញ្ញ ដែលហ៊ានលះបង់សេចក្តី

សុខផ្ទាល់ខ្លួន ជាពលរដ្ឋល្អថ្លៃថ្នូរ ក្នុងគោលដៅនាំចម្រើនដល់លទ្ធិប្រជាធិបតេយ្យ យុត្តិធម៌សង្គម និងបុព្វហេតុទឹកដីជាតិ ។ សកម្មភាពពលិកម្មរបស់ពួកគាត់ គឺដើម្បីប្រយោជន៍ជាតិយើងទាំងអស់គ្នា ដែលប្រកាសទទួលស្គាល់ដោយក្រុមអ្នកសង្កេតការណ៍គ្រប់មជ្ឈដ្ឋាន ទាំងអ្នកការទូត ជាតំណាងនៃអង្គការសហប្រជាជាតិ សហភាពអឺរ៉ុប និងបណ្ដាប្រទេសប្រជាធិបតេយ្យធំៗ ជាពិសេស សហរដ្ឋអាមេរិក ។

សមាជិកសភាអាមេរិក **អាឡែន ឡូវ៉េនថល** (Congressman Alan Lowenthal) មានប្រសាសន៍ថា « **សកម្មជនទាំងអស់ គួរទទួលបាននូវការសាទរលើកទឹកចិត្ត គឺពុំមែនដាក់ពន្ធនាគារទេ ។ ពួកគាត់គឺជាអនាគតកម្ពុជា** » ។ ឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក ទទួលបន្ទុកលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ លោក **រ៉ូប៊ឺត អេ. ដេស្ត្រូ** (Robert A. Destro) បានរំឭកថា « **សិទ្ធិសេរីភាពបញ្ចេញមតិ និងសិទ្ធិសេរីភាពនៃការជួបជុំគ្នា មានចែងក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ។ សហរដ្ឋអាមេរិក ព្រួយបារម្ភយ៉ាងខ្លាំងចំពោះការចាប់ខ្លួន អ្នកដែលអនុវត្តសេរីភាពទាំងនេះ ហើយយើងទទូចឲ្យរដ្ឋាភិបាល ដោះលែងពួកគាត់ជាបន្ទាន់ និងអនុញ្ញាតឲ្យពួកគាត់អាចបញ្ចេញមតិបាន** » ។

លោកស្រី **រ៉ូណា ស្មីត** ( Rhona Smith ) អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិ ផ្នែកសិទ្ធិមនុស្សនៅកម្ពុជា និងជាអ្នកតាមដានស្ថានការណ៍កម្ពុជាយ៉ាងជិតដល់ ក៏បានសម្ដែងកង្វល់ចំពោះការចាប់ខ្លួនសកម្មជនខ្មែរជាបន្តបន្ទាប់ ។ លោកស្រី មានប្រសាសន៍ថា « **សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ បង្កើតសមាគម និងការជួបប្រជុំដោយសន្តិវិធី ត្រូវបានការពារដោយនិយាម និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ក៏ដូចជារដ្ឋធម្មនុញ្ញកម្ពុជាផងដែរ** » ។ លោកស្រី ជម្រុញឲ្យអាជ្ញាធរកម្ពុជា « **ធានាថា សិទ្ធិទាំងនេះត្រូវបានគោរព និងការពារ ហើយបង្កើតបរិយាកាសមួយ ដែលបុគ្គលម្នាក់ៗអាចអនុវត្តសិទ្ធិទាំងនេះ** » ។

ប្រជាពលរដ្ឋខ្មែរគ្រប់មជ្ឈដ្ឋាន អ្នកស្ថានការណ៍ជាតិនិងអន្តរជាតិ ដៃគូវិនិយោគបរទេសធំៗ និងសហគមន៍ម្ចាស់ជំនួយអន្តរជាតិ ***ដឹងច្បាស់ណាស់ថា*** ការចាប់ឃុំខ្លួនព្រះសង្ឃ ក្រុមយុវជន និងយុវតីថ្មីៗនេះ គឺជាការរំលោភលើច្បាប់បាតុកម្មដោយសន្តិវិធី និងជាពិសេសបំពានយ៉ាងធ្ងន់ធ្ងរ លើខ្លឹមសាររដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។ ពេលរដ្ឋាភិបាលខ្លួនឯង មិនគោរពច្បាប់ដោយខ្លួនឯង គឺជា

ការមើលងាយប្រជាពលរដ្ឋខ្មែរម្ចាស់ប្រទេសផង និងជាការចំអកខ្លាំងណាស់ ចំពោះសហគមន៍អន្តរជាតិ ដែលតែងតែមានសមានចិត្តជួយជ្រោមជ្រែងជីវភាពពលរដ្ឋខ្មែរទូទៅផង ។

ប្រជាពលរដ្ឋខ្មែរគ្រប់មជ្ឈដ្ឋាន អ្នកស្ថានការណ៍ជាតិនិងអន្តរជាតិ ដៃគូវិនិយោគបរទេសធំៗ និង សហគមន៍ម្ចាស់ជំនួយអន្តរជាតិ ***ដឹងច្បាស់ណាស់ថា*** រដ្ឋាភិបាលនៃលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ប្រើប្រាស់បទញុះញង់ឲ្យប្រព្រឹត្តបទល្មើស គន្លីទី៤ មាតិកាទី១ ជំពូកទី៣ ផ្នែកទី៣ នៃក្រមព្រហ្មទណ្ឌ ដែលមានវិសមិតភាពនឹងខ្លឹមសាររដ្ឋធម្មនុញ្ញ ដើម្បីជាមធ្យោបាយបំភិតបំភ័យពលរដ្ឋស្លូតត្រង់ ដែលចង់ បញ្ចេញមតិ និងចាប់អ្នកតវ៉ាអហិង្សា ដាក់គុកងាយៗ ។ ពេលរដ្ឋាភិបាលខ្លួនឯង ប្រើឈ្មោះច្បាប់ដើម្បី ធ្វើទុក្ខបុកម្នេញពលរដ្ឋជាតិឯងបែបនេះ គឺជាការបំបាក់ស្មារតីជាតិឯងផង បន្លាចក្រុមវិនិយោគិនបរទេស ល្អៗផង និងធ្វើឲ្យសហគមន៍ម្ចាស់ជំនួយអន្តរជាតិធំៗ ធុញទ្រាន់នឹងស្ថានភាពកម្ពុជាផង ព្រោះឃើញ តែទង្វើបំភ្លៃ និងការបំភ័ន្តរបស់រដ្ឋាភិបាលកម្ពុជា ។

ប្រជាពលរដ្ឋខ្មែរគ្រប់មជ្ឈដ្ឋាន អ្នកស្ថានការណ៍ជាតិនិងអន្តរជាតិ ដៃគូវិនិយោគបរទេសធំៗ និង សហគមន៍ម្ចាស់ជំនួយអន្តរជាតិ ***ដឹងច្បាស់ណាស់ថា*** រដ្ឋាភិបាលនៃលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** កំពុងតែដឹកនាំប្រាសចាកកាន់តែឆ្ងាយពីគោលការណ៍ប្រជាធិបតេយ្យ និងសន្តិភាព ដោយការប្រើប្រាស់ វិធីចោទប្រកាន់ខ្មែរជាតិឯង ជាជនក្បត់ជាតិ ឬជាឧទ្ទាមក្រៅច្បាប់ ពេលមានទស្សនៈផ្ទុយគ្នាអំពីវិវត្តន៍ សង្គម ។ **លទ្ធិប្រជាធិបតេយ្យរឹងមាំ និងសន្តិភាពសុខសាន្តពិត សម្រាប់ប្រទេសជាតិមួយ ជាសកល គឺទាល់តែមានគោលការណ៍ដំណោះស្រាយនូវរាល់ជម្លោះ និងការខ្វែងគំនិតគ្នា ដោយគ្មានអំពើហិង្សា គ្រប់ទម្រង់ ព្រមទាំងការផ្សះផ្សាគ្នាជាមូលដ្ឋាន គឺពុំមែនទង្វើសម្លុតបំភ័យ ខ្មោះ និងគុកទេ នៅពេល ភាគីណាមួយ គ្រាន់តែសម្តែងទស្សនៈមតិរបស់ពួកគេនោះ ។**

ករណីទាំងអស់នេះ កំពុងធ្វើឱ្យអ្នកវិនិយោគធំៗ ដៃគូអភិវឌ្ឍន៍នានា និងសហគមន៍អន្តរជាតិ មើលមកមេដឹកនាំកម្ពុជា ក្នុងផ្លូវកាន់តែអាក្រក់ ។ ពលរដ្ឋខ្មែរកំពុងធ្លាក់ក្នុងស្ថានភាពជូរចត់ បាត់ការងារ ជាប់បំណុលវ័ណ្ឌក និងរអិលចូលគ្រោះទុរភិក្ស ។ រដ្ឋាភិបាល កំពុងប្រឈមសម្ពាធធ្ងន់ធ្ងរពីសហគមន៍ អន្តរជាតិលោកសេរីប្រជាធិបតេយ្យ ៖ សហភាពអឺរ៉ុបព្យួរប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្ម អ៊ីប៊ីអេ(EBA)

២០% និងនិន្នាការនៃការដាក់កម្ពុជាក្នុងបញ្ជីខ្មៅនៃបណ្តាប្រទេសលាងលុយកខ្វក់ ព្រមទាំងសហរដ្ឋអាមេរិក ដាក់ទណ្ឌកម្មលើក្រុមហ៊ុនអាជីកម្មមន្ត្រីជាន់ខ្ពស់ខ្មែរ-ចិន ។ ប្រទេសជាតិកម្ពុជា បាត់កេរ្តិ៍ឈ្មោះ និងលស់ព្រលឹងជាតិ ដែលរុំរុកដោយវិបត្តិបំណុលបរទេស និងជម្ងឺជម្លោះផ្ទៃក្នុងជាតិ ។

រដ្ឋមន្ត្រីក្រសួងការបរទេស លោក **ម៉ៃឃើល ផុមភេអូ (Michael R. Pompeo)** ថ្លែងបញ្ជាក់ច្បាស់ នូវគោលជំហររបស់សហរដ្ឋអាមេរិកថា **« យើងនឹងមិនលើកលែងឱ្យសកម្មភាពទាំងឡាយណាដែលប្រឆាំងនឹងជនស្លូតត្រង់ ហើយសហរដ្ឋអាមេរិកនឹងឈរការពារប្រជាពលរដ្ឋខ្មែរជានិច្ច »** ។ លោក **ឯកអគ្គរាជទូតខ្មែរប្រចាំអាមេរិក** និងលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** *ដឹងច្បាស់ណាស់ថា* ជំហរការទូត និងការសម្រេចចិត្តនានារបស់សហរដ្ឋអាមេរិក មានលក្ខណៈជា តំណាងឥទ្ធិពលធំណាស់លើជំហរការទូតនៃអង្គការសហប្រជាជាតិ បណ្តាប្រទេសក្នុងសហភាពអឺរ៉ុប និងក្រុមប្រទេសសម្ព័ន្ធមិត្តលោកសេរីផ្សេងទៀត ដូចជា កាណាដា អង់គ្លេស ជប៉ុន និងអូស្ត្រាលី ជាដើម ។

យើងខ្ញុំ មើលឃើញថា ប្រទេសកម្ពុជាយើង នឹងត្រូវជួបវិបត្តិធំៗច្រើនទៀត ជាពិសេសរងសម្ពាធពីភាគីសហគមន៍អន្តរជាតិប្រជាធិបតេយ្យ ប្រសិនបើរដ្ឋាភិបាលនៃលោក **ហ៊ុន សែន** មិនសម្រួលស្ថានការណ៍នយោបាយ ទៅកាន់ការស្តារប្រជាធិបតេយ្យដ៏ក្មេងខ្ចីរបស់កម្ពុជាឡើងវិញ ។

ដើម្បីស្តារមុខមាត់កម្ពុជាយើង សូមនាយករដ្ឋមន្ត្រី **ហ៊ុន សែន ចាប់ផ្តើមដោះលែងអ្នកទោសមនសិការ និងអ្នកទោសនយោបាយទាំងអស់ ។** យើងខ្ញុំ ក៏ទាមទារឲ្យរដ្ឋាភិបាលនៃលោក **ហ៊ុន សែន ស្នើទៅសភាកម្ពុជា ធ្វើវិសោធនកម្មលុបចោល « បទញុះញង់ឲ្យប្រព្រឹត្តបទល្មើស » ដើម្បីធានាសេរីភាពបញ្ចេញមតិ និងការជួបជុំសម្តែងមតិរបស់ពលរដ្ឋ ដោយគ្មានការភ័យខ្លាច ឲ្យស្របនឹងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ព្រមទាំងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ។**

សូមលោក **ឯកអគ្គរាជទូត** បញ្ជូនញត្តិរបស់យើងខ្ញុំ ទៅកាន់រដ្ឋាភិបាលកម្ពុជា ឲ្យបានឆាប់ ហើយយើងខ្ញុំសង្ឃឹមថា លោក**ឯកអគ្គរាជទូត** មានសេចក្តីក្លាហានគ្រប់គ្រាន់ នឹងបំពេញតួនាទីជូនយោបល់ដល់លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន ឲ្យដោះលែងក្រុមអ្នកទោសមនសិការ និង អ្នកទោស**

នយោបាយគ្រប់រូប ជាបន្ទាន់ និងឲ្យលោកនាយករដ្ឋមន្ត្រី ចេះបន្ទន់ឥរិយាបថរកការផ្សះផ្សាជាតិ ដើម្បីស្តារកិត្តិយសប្រទេសជាតិកម្ពុជា តាមការចង់បានរបស់ប្រជាពលរដ្ឋខ្មែរទូទៅ ក្រុមវិនិយោគិនបរទេសដែលមានសក្តានុពលល្អៗ ដៃគូអភិវឌ្ឍន៍នានា និងសហគមន៍អន្តរជាតិម្ចាស់ជំនួយធំៗរបស់កម្ពុជា ។

ធ្វើនៅរដ្ឋធានីវ៉ាស៊ីតុន ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០

**ហត្ថលេខា**

TOUCH VIBOL
North Carolina, USA

TY YOK
Chicago

LIM ROSS
NC

WOOTE PHROM
IL

Chicago
DANNY THACH
Danny thach MD

NaPandita TK Rithypol, MD

Bophia So